YUNNAN DAILY PRESS GROUP

# សម្រស់ យូនណាន

YUNNAN DAILY PRESS GROUP
english.yunnan.cn

ឆ្នាំទី 23 លេខ 6735 ថ្ងៃសៅរ៍ ទី 30 ខែឧសភា ឆ្នាំ 2015

## ការរៀបចំបម្រុងនៃពិព័រណ៍ពាណិជ្ជកម្មអាស៊ីខាងត្បូងបានដំណើរការដោយរលូន





តាមព័ត៌មានពេលថ្មីនេះថា ការរៀបចំបម្រុងនៃពិព័រណ៍ពាណិជ្ជកម្មអាស៊ីខាងត្បូង បានដំណើរការដោយរលូនណាស់ ។

យោងតាមរបាយការណ៍ពិព័រណ៍ពាណិជ្ជកម្មអាស៊ីខាងត្បូងសម័យទី៣ នេះ ខេត្តយូនណានបានផ្ញើចេញលិខិតអញ្ជើញចំពោះប្រទេសចំនួន៥៣២តំបន់ និងអង្គការអន្តរជាតិចំនួន២ ហើយបានទទួលផលល្អណាស់ក្នុងការអញ្ជើញភ្ញៀវវិអាយភី និងប្រមូលពាណិជ្ជករ ។ រហូតមកដល់ពេលនេះ មានសហគ្រាសល្បីល្បាញចំនួន៨៣បានបញ្ជាក់ថា នឹងមកចូលរួម ព្រមទាំងសហគ្រាសខ្លាំងពូកែជាងគេទូទាំងពិភពលោកចំនួន ២៤ និងសហគ្រាសខ្លាំងពូកែជាងគេក្នុងស្រុកចំនួន៨ ។ មានខេត្តចំនួន២៥ក្នុងស្រុកចិននិងប្រទេសចំនួន៧៥ និងមកចូលរួមពិព័រណ៍ពាណិជ្ជកម្មលើកនេះ ព្រមទាំងប្រទេសចំនួន ៨ នៃអាស៊ីខាង ត្បូង និងប្រទេសចំនួន១០នៃអាស៊ីអាគ្នេយ៍ ។ ភារកិច្ចអំពីការប្រមូលពាណិជ្ជករត្រូវបានបំពេញយ៉ាងល្អប្រសើរ ឥឡូវខេត្តយូនណានកំពុងខំប្រឹងដើម្បីលើកឡើងគុណភាពនៃពិព័រណ៍ពាណិជ្ជកម្មអាស៊ីខាងត្បូងលើកនេះ ។



ម្យ៉ាងទៀត ការកសាងនៃមជ្ឈមណ្ឌលតាំងពិព័រណ៍ និងការរៀបចំកន្លែងតាំងពិព័រណ៍ក៏ត្រូវអនុវត្តន៍យ៉ាងរលូន ។ មជ្ឈមណ្ឌលតាំងពិព័រណ៍ថ្មីនេះ មានរោងតាំងពិព័រណ៍ចំនួន១២ ដែលមានទំហំសរុប ១២៣.០០០ម៉ែត្រក្រឡា តំបន់តាំងពិព័រណ៍ក្រៅផ្ទះ ៧.០០០ម៉ែត្រក្រឡា មានទ្រង់ទ្រាយប្រហែលពីរដងបើប្រៀបធៀបនឹងពិព័រណ៍ពាណិជ្ជកម្មអាស៊ីខាងត្បូងសម័យមុន ហើយមានកម្រិតអន្តរជាតូបនីយកម្មកាន់តែខ្ពស់ឡើងចំនួននៃកន្លែងតាំងពិព័រណ៍សម្រាប់បរទេសបានឡើងដល់ ៥០ ភាគរយ នៃចំនួនកន្លែងតាំងពិព័រណ៍ទាំងអស់ ។ ពិព័រណ៍ពាណិជ្ជកម្មអាស៊ីខាងត្បូងឆ្នាំនេះនឹងចាត់ចែងរោងតាំងពិព័រណ៍សម្រាប់ក្រុងមេត្រីភាពជាលើកដំបូងនៅប្រទេសចិន ៕

**គិន សៀវបូ**

## ប្រទេសចិននិងឥណ្ឌានឹងរួមគ្នាបង្កើតមហាវិទ្យាល័យយូហ្គាដំបូងនៅក្នុងខេត្តយូនណាន

ពេលថ្មីៗនេះ នៅរដ្ឋធានីប៉េកាំង សកលវិទ្យាល័យជនជាតិយូនណាន និងគណៈកម្មាធិការទំនាក់ទំនងខាងវប្បធិមនៃប្រទេសឥណ្ឌា បានចុះហត្ថលេខាលើអនុស្សរណៈកិច្ចសហប្រតិបត្តិការ អំពីការរួមគ្នាបង្កើតឡើងមហាវិទ្យាល័យយូហ្គាមួយនៅក្នុងសកលវិទ្យាល័យជនជាតិយូនណាននេះ គឺជាមហាវិទ្យាល័យយូហ្គាទីមួយរបស់ប្រទេសឥណ្ឌានៅប្រទេសចិន ។

ការបង្កើតឡើងនៃមហាវិទ្យាល័យយូហ្គា នឹងកសាងវេទិកាទាក់ទងគ្នាយ៉ាងទូលំទូលាយមួយខាងអប់រំ និងវប្បធមិសម្រាប់ការទាក់ទងគ្នារវាងប្រទេសចិន និងឥណ្ឌា នៅវិស័យវប្បធមិ ។ ប្រទេសទាំងពីរនឹងយកការទាក់ទងខាងអប់រំ និងវប្បធមិគ្នាជាចំណងមួយ ដើម្បីជំរុញការសហប្រតិបត្តិការគ្នាខាងអប់រំ បង្កើនការយល់ដឹងពីគ្នាទៅវិញទៅមក និងការជឿទុកចិត្តគ្នា ដើម្បីបម្រើយុទ្ធសាស្ត្រ "ខ្សែក្រវាត់មួយនិងផ្លូវមួយ" និងការសាងសង់នៃ "ច្រករបៀងសហការខាងសេដ្ឋកិច្ចបង់ក្លាដែស-ចិន-ឥណ្ឌា-ភូមា" ឱ្យកាន់តែល្អប្រសើរ ។ តាមរយៈការបង្កើតឡើងនៃមហាវិទ្យាល័យយូហ្គាខេត្តយូនណាន និងប្រទេសឥណ្ឌា នឹងអនុវត្តន៍ផែនការ "ដៃគូខាងអប់រំរវាងខេត្តយូនណាន និងប្រទេសឥណ្ឌា" ជាមួយគ្នា ហើយកសាងវេទិកាសហការថ្មីមួយ ដើម្បីដើរតួអង្គរបស់ខេត្តយូនណានដែលឈ្មោះថា "មជ្ឈមណ្ឌលជាវិទ្យុសកម្មនៃអាស៊ីខាងត្បូង និអាស៊ីអាគ្នេយ៍" ឱ្យបានល្អ ។

តាមការណែនាំថា ខែកញ្ញា ឆ្នាំនេះ មហាវិទ្យាល័យយូហ្គានឹងជ្រើសរើសសិក្ខាកាមជំនាន់ទីមួយ (ការអប់រំមិនចែកសញ្ញាបត្រ) ។ មនុស្សដែលចូលចិត្តកីឡាយូហ្គា ព្រមទាំងគ្រូបង្រៀនយូហ្គា និងនិស្សិតក្នុងសាលានានាជាដើមសុទ្ធតែអាចចុះឈ្មោះចូលរួមបាន ។ មហាវិទ្យាល័យយូហ្គា មានគោលបំណងដើម្បីបណ្តុះបណ្តាលអ្នកជំនាញនៅគ្រប់កម្រិតទាំងអស់នៃកីឡាយូហ្គា ដើម្បីស្វែងយល់អំពីទស្សនវិជ្ជាឥណ្ឌារីករាលដាលនៃវប្បធមិយូហ្គា ។គណៈកម្មាធិការទំនាក់ទំនងខាងវប្បធមិនៃប្រទេសឥណ្ឌានឹងចាត់ចែង គ្រូបង្រៀនដ៏មានជំនាញវិជ្ជាជីវៈយូហ្គាយ៉ាងហោចពីរនាក់មកប្រទេសចិន ហើយធ្វើការបង្រៀនយូហ្គា និងរៀបចំបើកវគ្គសិក្សាយូហ្គាអន្តរជាតិ ។ និស្សិតទាំងអស់នៅមានឱកាសទៅបំពេញការសិក្សាយូហ្គានៅប្រទេសឥណ្ឌា ។ ក្រសួងយូហ្គាប្រទេសឥណ្ឌានឹងធ្វើការប្រឡងចំពោះនិស្សិតនៃមហាវិទ្យាល័យយូហ្គាយើង ហើយនឹងចែកវិញ្ញាបនបត្រយូហ្គាដែលគេទទួលស្គាល់ជាអន្តរជាតិមួយ ៕

**លី សាគិន**

## លោក Jhon បង្កើតគ្រួសារនៅជនបទនៃស្រុកលាន់ឆាំង

ខ្ញុំមានមិត្តភក្តិបរទេសជាច្រើន ប៉ុន្តែមិត្តភក្តិដូច Jhon បែបនេះ មានតែម្នាក់ទេ។

ថ្ងៃមួយនៃរដូវក្តៅមួយ ខ្ញុំបានមកដល់ភូមិមួយនៃស្រុកលាន់ឆាំង ដើម្បីធ្វើការជួយបង្រៀននៅភូមិនេះ ជាមួយនឹងសមាគមអ្នកស្ម័គ្រចិត្តយុវជននៃសាលាយើង។ ខ្ញុំមានក្តីសុបិនមួយជានិច្ចដែលមានឱកាសទៅធ្វើការខ្លះមានប្រយោជន៍ចំពោះក្មេងៗដែលរស់នៅជនបទបែបនេះ។ ប៉ុន្តែអ្វីដែលធ្វើឱ្យខ្ញុំមានការភ្ញាក់ផ្អើលនោះ គឺមិត្តភក្តិបរទេសគួរឱ្យគោរពកោតសរសើរមនុស្សម្នាក់ដែលខ្ញុំបានស្គាល់ក្នុងការជួយទៅបង្រៀនលើកនេះ។

លោកនេះឈ្មោះ Jhon គឺជនជាតិអាមេរិក ដែលមានអាយុជាង ៥០ឆ្នាំគឺជាមនុស្សស្មោះត្រង់ម្នាក់ ហើយចេះភាសាចិនជ្រៅជ្រះ។លើកដំបូងដែលខ្ញុំបានប្រទះគាត់ គឺគាត់កំពុងជួយងូតទឹកឱ្យកូនប្រុសម្នាក់ក្នុងភ្នែកគាត់គឺពោរពេញទៅដោយសេចក្តីស្រឡាញ់។ កូនប្រុសនោះគឺឈ្មោះ អាលាំង អាយុ៥ឆ្នាំ ជាក្មេងកំព្រាម្នាក់ ដែលលោក Jhon នាំមកវិញ ដើម្បីសុំចិញ្ចឹមថែរក្សា។

លោក Jhon ប្រាប់ខ្ញុំថា លោកធ្លាប់ជាអ្នកធ្វើដំណើរម្នាក់ ហើយធ្លាប់ធ្វើដំណើរបានពាក់កណ្តាលនៃប្រទេសចិន នៅទីបំផុតគាត់សម្រេចចិត្តថារស់នៅខេត្តយូនណាន ដែលជាទឹកដីស្រស់បំព្រង។ សម្រាប់លោក Jhon ភាពស្អាតបាតនៃទេសភាពធម្មជាតិនិងភាពស្មោះត្រង់នៃអ្នកស្រុកទាំងអស់សុទ្ធតែការទាក់ទាញមិនអាចបដិសេធដែរ។ បីឆ្នាំកន្លងផុតទៅហើយ ក្នុងបីឆ្នាំនេះ លោករៀនភាសាចិនផង ជួយទៅបង្រៀនភាសាអង់គ្លេសផង។

នៅពេលដំបូង មនុស្សគ្រប់រូបសង្ស័យថា នៅក្រោមបរិវេណបែបអាក្រក់នេះ លោក Jhon ដែលជាជនបរទេសម្នាក់ មុខជានឹងប្រកាន់មិនយូរប៉ុន្មានទេ។ ប៉ុន្តែក្រោយមក គាត់បានឱ្យអ្នកទាំងអស់ឃើញថា លោកមានមនោគតិរបស់ខ្លួន ហើយបានទទួលការជឿទុកចិត្តនិងគោរពពីមនុស្សគ្រប់រូប។ លោក Jhon បានផ្ញើមកសៀវភៅ និងប្រដាប់សិក្សាជាច្រើនពីសហរដ្ឋអាមេរិកឱ្យកូនៗក្នុងតំបន់នេះដើម្បីឱ្យកូនក្មេងទាំងនេះមានឱកាសកាន់តែច្រើនយល់ស្គាល់ពីពិភពលោកខាងក្រៅ ។

"នៅពេលខ្ញុំមើលឃើញដល់ការស្រេកឃ្លានចំពោះចំណេះវិជ្ជាក្នុងភ្នែកកូនក្មេងទាំងនេះ ខ្ញុំក៏គិតថា ការដែលខ្ញុំបានធ្វើទាំងនោះ ពិតជាមានតម្លៃណាស់។" និយាយដោយលោក Jhon ។ ស្មារតីរបស់លោក Jhon បែបនេះ បានភ្ញាក់ផ្អើលដល់ខ្ញុំយ៉ាងខ្លាំង។

ឆ្នាំទៅ ការដែលលោក Jhon បានសុំកូនចិញ្ចឹមនោះ បានរាលដាលដល់ភូមិនេះទាំងមូល អ្នកស្រុកទាំងអស់បានទុកលោកជាអ្នកស្រុកនៃភូមិនេះហើយ។ បើមានគ្រួសារណាបានសម្លាប់សត្វហើយសុទ្ធតែពុំភ្លេចទៅអញ្ជើញលោក Jhon និងកូនរបស់គាត់ជាដាច់ខាត។ នៅពេលទំនេរ គាត់ក៏ធ្វើម្ហូបចិនប៉ុន្មានយ៉ាង ហើយអញ្ជើញអ្នកស្រុកមកផ្ទះខ្លួនដើម្បីប្រជុំជាមួយគ្នា ហើយច្រៀងជាមួយគ្នា ទទួលទាន ការរស់នៅបែបយូនណានដ៏សេរី និងស្រួល។

ខ្ញុំធ្លាប់សួរលោកថា លោកនឹងរស់នៅនៅខេត្តយូនណានរហូតទេ? គាត់ឆ្លើយថា "បាទ មុខជានឹងកន្លែងនេះមានកូនសិស្សខ្ញុំ កូនខ្ញុំនិងផ្ទះខ្ញុំ"៕ **ស៊ូវិន**

## ការសម្តែងដើរលើខ្សែដែកថែបរវាងអគារភ្លោះ

បច្ចុប្បន្ននេះ ការសម្តែងដើរលើខ្សែដែកថែបរវាងអគារភ្លោះ ដែលមានកម្ពស់ ៣០០ម៉ែត្រនោះ បានធ្វើឡើងនៅទីផ្លាវ៉ាន់ដា នៃសង្កាត់ស៊ីសាន ក្រុងគុនមីញ។ លោកអៃស្កែល ម្ចាស់កំណត់ត្រាពិភពលោក Guinness ទាំងប្រាំមួយប្រការ បានដើរលើខ្សែដែកថែបនៅកម្ពស់ខ្ពស់រវាងអគារភ្លោះវ៉ាន់ដា ដោយបិទភ្នែក ហើយដើរថយក្រោយបានជាប់កំណត់ត្រាពិភពលោកថ្មីមួយ។

ម៉ោង ៥ល្ងាចនេះ អាកាសធាតុបានចាប់ផ្តើមក្លាយទៅជាត្រជាក់ស្រួល លោក អៃស្កែល បានមកដល់ ជាន់ទី៣២ នៃអគារភ្លោះខាងត្បូង ហើយដើម្បីធ្វើការបម្រុងសម្រាប់ការដើរលើខ្សែដែកថែប។ ទន្ទឹមនឹងនេះ នៅក្នុងទីផ្លាវ៉ាន់ដា បានប្រជុំទស្សនិកជនជាច្រើន។

ម៉ោង៦ល្ងាច លោកអៃស្កែល បានបង្ហាញខ្លួននៅក្នុងទស្សនវិស័យរបស់មនុស្សទាំងអស់ដែលមកទស្សនា គាត់បានដើរចេញពីអគារខាងត្បូងឆ្ពោះទៅអគារខាងជើងដោយបិទភ្នែក ហើយថយក្រោយ។ នេះគឺគ្រាន់តែធ្វើការសាកល្បងទៅចុះ ប៉ុន្តែទស្សនិកជនទាំងអស់បានហ៊ោកញ្ជ្រៀវឡើងហើយ។

បន្ទាប់មក លោកអៃស្កែលបានចាប់ផ្តើមដើរលើខ្សែដែកថែបជាផ្លូវការក្រោមការទស្សនានៃអ្នកមើលទាំងឡាយ លោកបានទទួលជោគជ័យដោយអស់ពេល១៥នាទី។ ហើយបន្ទាប់មក លោកបានសម្តែងការដើរលើខ្សែដែកថែបបែបផ្សេងទៀត បានទទួលការកោតសរសើរខ្លាំងណាស់ ។ ដូច្នេះ ហើយកំណត់ត្រាពិភពលោកទីមួយអំពីការដើរលើខ្សែដែកថែបនៃទីក្រុងគុនមីញ បានកើតឡើងហើយ ។

តាមការណែនាំថា អគារភ្លោះវ៉ាន់ដា គឺជាអគារភ្លោះខ្ពស់ជាងគេបំផុតក្នុងប្រទេសចិន គឺជាអគារការិយាល័យថ្នាក់ 5A មួយដែលមានកម្ពស់ ៣០០ម៉ែត្រ អគារភ្លោះវ៉ាន់ដាចែកជាអគារភាគខាងជើងនិងភាគខាងត្បូង។ ខ្សែដែកថែបដែលប្រើក្នុងការសម្តែងលើកនេះមានប្រវែង១០០ម៉ែត្រ ហើយមានកម្ពស់១៥០ ម៉ែត្រពីដី៕ **កៅ វ៉ៃ**



